ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ធំ

សំណុំរឿងរដ្ឋប្បវេណីលេខ:១១៩

ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣

សាលក្រមរដ្ឋប្បវេណីលេខ: ៨ "ក"

ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ធំ

-បានឃើញច្បាប់ស្តីពីការរៀបចំអង្គការតុលាការប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

-បានឃើញមាត្រា៧៥ មាត្រា១៨២ និងមាត្រា១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-បានបើកនិងបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការ នៃសាលាដំបូងខេត្តកំពង់ធំ នាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ លើសំណុំរឿងរដ្ឋប្បវេណីលេខ:១១៩ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ ចាប់ពីវេលាម៉ោង ប្រាំបួន និង សាមសិបនាទី ដល់ម៉ោង ដប់ និង ប្រាំ នាទី ព្រឹក ដោយមានសមាសភាពដូចតទៅ៖

**<u>ចៅក្រមជំនុំជម្រះ</u>**

**ឯកឧត្តម [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ធំ**

**<u>ក្រឡាបញ្ជីសវនាការ</u>**

**លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ធំ**

រវាងដើមចោទឈ្មោះ [redacted] ធារី ភេទស្រី កើតឆ្នាំ១៩៨៤ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ទីលំនៅបច្ចុប្បន្ននៅ [redacted] ឪពុកឈ្មោះ [redacted] ពឿន (រស់) ម្តាយឈ្មោះ [redacted] ស្រេង (ស្លាប់) ប្តីឈ្មោះ [redacted] វិត មានកូនចំនួន ២ នាក់ មុខរបរ គ្រូបង្រៀនបឋមសិក្សា កម្រិតវប្បធម៌ ថ្នាក់ទី១២ ទោសពីមុន គ្មាន ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

និងចុងចម្លើយឈ្មោះ [redacted] វិត ភេទប្រុស កើតឆ្នាំ១៩៨១ សញ្ជាតិខ្មែរ ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ននៅ [redacted] ឪពុកឈ្មោះ [redacted] ឆាត (រស់) ម្តាយឈ្មោះ [redacted] ហួត (រស់) ប្រពន្ធឈ្មោះ [redacted] ធារី មានកូនចំនួន ០២នាក់ មុខរបរ មន្ត្រីសាលាស្រុកប្រាសាទបល្ល័ង្ក កម្រិតវប្បធម៌ ថ្នាក់បរិញ្ញាបត្រ ទោសពីមុនគ្មាន ។

កម្មវត្ថុបណ្តឹង៖ ប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តីឈ្មោះ ឆាត វិត



Scanned with CamScanner

## អង្គហេតុ និងចំណុចទំនាស់

**ក-អង្គហេតុ៖**

កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ប៉ុន្តែមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍នោះ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ទើបដើមចោទ និងចុងចម្លើយ នាំគ្នាចុះបញ្ជីអាពាហ៍ពិពាហ៍ ហើយនៅក្នុងអំឡុងអាពាហ៍ពិពាហ៍ គូភាគី មានកូនចំនួន ២នាក់ គឺ កូនទី១ ឈ្មោះ [redacted] រចនាសុភាវី ភេទស្រី សញ្ជាតិខ្មែរ កើតនៅថ្ងៃ០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ និងកូនទី២ ឈ្មោះ [redacted] សុនីតា ភេទស្រី សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ។ ក្រោយមក ការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ចេះតែឈ្លោះប្រកែកគ្នា ប្រើអំពើហិង្សាទៅវិញទៅមក អស់មនោសញ្ចេតនាជាប្តីប្រពន្ធ ដូច្នេះហើយ ទើបដាក់ពាក្យបណ្តឹងលែងលះមកតុលាការតែម្តង។

**ខ-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

១-ប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តីឈ្មោះ [redacted] រ៉ិត ។

២-ដើមចោទសុំសិទ្ធគ្រប់គ្រងកូនឈ្មោះ [redacted] រចនាសុភាវី ភេទស្រី សញ្ជាតិខ្មែរ កើតនៅថ្ងៃ០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ និងកូនឈ្មោះ [redacted] សុនីតា ភេទស្រី សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ និងបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់អាហារកិច្ចចំពោះកូនទាំងពីរនាក់ ៥០ (ហាសិប) ដុល្លារអាមេរិក ក្នុងមួយខែ រហូតដល់កូនពេញនីតិភាព ។

៣-ពោះទ្រព្យសម្បត្តិរួមសុំបែងចែកដូចខាងក្រោម៖

១-ឡានចំនួន ០១ (មួយ) គ្រឿង ម៉ាក CAMRY ផលិតឆ្នាំ២០០២ ពណ៌ទឹកមាស ពាក់ផ្លាកភ្នំពេញលេខ 2AI-2334 ជាទ្រព្យរួមប្តីប្រពន្ធ សុំប្រគល់ឱ្យមកដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ ដោយដើមចោទយល់ព្រមប្រគល់ប្រាក់ចំនួន ៣.៥០០ (បីពាន់ ប្រាំរយ) ដុល្លារអាមេរិក ឱ្យទៅចុងចម្លើយ។

២-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ៨,៣០ (ប្រាំបីក្បៀសសាមសិប) ម៉ែត្រ គុណនឹង ១៧០ (មួយរយចិតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] ផាង , ខាងត្បូងទល់ [redacted] ជួ , ខាងកើតទល់ ផ្លូវជាតិលេខ៦២ និងខាងលិចទល់ [redacted] គឿន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្លង់ដីលំនៅដ្ឋានលេខ <u>១៣៧/១៧</u> ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ចេញដោយ លោក [redacted] មេឃុំសាលាវិស័យ ជាទ្រព្យដើមរបស់ដើមចោទ សុំប្រគល់ឱ្យមកដើមចោទជាគ្រប់គ្រងជាកម្មសិទ្ធិ។

៣-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ២០ (ម្ភៃ) ម៉ែត្រ គុណនឹង ៨០ (ប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] កែវ , ខាងត្បូងទល់ ឈុំ លីហោង , ខាងកើតទល់ [redacted] ផាណូល និងខាងលិចទល់ ផ្លូវជាតិ ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់កម្មសិទ្ធិលេខ <u>១៣១៤/១៩</u> ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយ លោក [redacted] មេឃុំសាលាវិស័យ ជាទ្រព្យនៃឪពុកម្តាយរបស់ដើមចោទ សុំប្រគល់ឱ្យទៅឪពុកម្តាយរបស់ដើមចោទជាគ្រប់គ្រងជាកម្មសិទ្ធិវិញ។

៤-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ១៤២ (មួយរយសែសិបពីរ) ម៉ែត្រ គុណនឹង ៣៨០ (បីរយប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ផ្លូវថ្នល់ , ខាងត្បូងទល់ [redacted] អ៊ិន , ខាងកើតទល់ [redacted] ប៊ិនថាន និងខាងលិចទល់ [redacted] អ៊ិន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្លង់ដីកម្មសិទ្ធិលេខ ១៣៧/២០ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ចេញដោយ លោក [redacted] មេឃុំសាលាវិស័យ ជាទ្រព្យនៃឪពុកម្តាយរបស់ដើមចោទ សុំប្រគល់ឱ្យទៅឪពុកម្តាយរបស់ដើមចោទជាគ្រប់គ្រងជាកម្មសិទ្ធិវិញ។

៥-ប្រាក់ជំពាក់នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ដែលមានប្រាក់កម្ចីដើមសរុបចំនួន ១០.០០០.០០០ (ដប់លាន) រៀល (និងការប្រាក់តាមតារាងកំណត់) ជាបំណុលរួមប្តីប្រពន្ធ សុំបែងចែកសងជាពីរចំណែកស្មើគ្នា។

៦-ប្រាក់ជំពាក់នៅ ធនាគារ អេស៊ីលីដា ដែលមានប្រាក់កម្ចីដើមសរុបចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល (និងការប្រាក់តាមតារាងកំណត់) ជាបំណុលរួមប្តីប្រពន្ធ សុំបែងចែកសងជាពីរចំណែកស្មើគ្នា។

៧-ប្រាក់ជំពាក់នៅ ធនាគារ អ៊ិរី (ខេមបូឌា) ម.ក ដែលមានប្រាក់កម្ចីដើមសរុបចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល (និងការប្រាក់តាមតារាងកំណត់) ជាបំណុលរួមប្តីប្រពន្ធ សុំបែងចែកសងជាពីរចំណែកស្មើគ្នា។

៨-ប្រាក់ជំពាក់នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ដែលមានប្រាក់កម្ចីដើមសរុបចំនួន ២៣.០០០ (ម្ភៃបីពាន់) ដុល្លារអាមេរិក (និងការប្រាក់តាមតារាងកំណត់) ជាបំណុលរួមប្តីប្រពន្ធ សុំបែងចែកសងជាពីរចំណែកស្មើគ្នា។

**គ-ការអះអាងរបស់គូភាគី ÷**

១).សេចក្តីថ្លែងការណ៍របស់ដើមចោទ:

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា: កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ប៉ុន្តែមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍នោះ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ទើបដើមចោទ និងចុងចម្លើយ នាំគ្នាចុះបញ្ជីអាពាហ៍ពិពាហ៍ ហើយនៅក្នុងអំឡុងអាពាហ៍ពិពាហ៍ គូភាគីមានកូនចំនួន ២នាក់ គឺកូនទី១ ឈ្មោះ [redacted] រចនាសុភាវី ភេទស្រី សញ្ជាតិខ្មែរ កើតនៅថ្ងៃ០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ និងកូនទី២ ឈ្មោះ [redacted] សុនីតា ភេទស្រី សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ។ ក្រោយមក ការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ចេះតែឈ្លោះប្រកែកគ្នា ប្រើអំពើហិង្សាទៅវិញទៅមក អស់មនោសញ្ចេតនាជាប្តីប្រពន្ធ ដូច្នេះហើយ ទើបដាក់ពាក្យបណ្តឹងលែងលះមកតុលាការតែម្តង។ ចំពោះកូនទាំងពីរនាក់ កូនក្តីរបស់ខ្ញុំបាទ សុំសិទ្ធិគ្រប់គ្រង និងសុំបែងចែកទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

១-ឡានចំនួន ០១ (មួយ) គ្រឿង ម៉ាក CAMRY ផលិតឆ្នាំ២០០២ ពណ៌ទឹកមាស ពាក់ផ្លាកភ្នំពេញលេខ 2AI-2334 ជាទ្រព្យរួមប្តីប្រពន្ធ ប្រគល់ឱ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិ ដោយចុងចម្លើយយល់ព្រមប្រគល់ប្រាក់ចំនួន ៥០០០ (ប្រាំពាន់ប្រាំរយ) ដុល្លារអាមេរិក ឱ្យទៅចុងចម្លើយ។

២-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ៨,៣០ (ប្រាំបីក្បៀសសាមសិប) ម៉ែត្រ គុណនឹង ១៧០ (មួយរយចិតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] ធាង , ខាងត្បូងទល់ [redacted] ជូ , ខាងកើតទល់ ផ្លូវជាតិលេខ៦២ និងខាងលិចទល់ [redacted] គឿន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិត



Scanned with CamScanner

បញ្ជាក់ប្លង់ដីលំនៅដ្ឋានលេខ ១៣៧/១៧ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ចេញដោយ លោក [redacted] មេឃុំសាលាវិស័យ ជាទ្រព្យដើមរបស់ដើមចោទ សុំប្រគល់ឱ្យមកដើមចោទជាគ្រប់គ្រងជាកម្មសិទ្ធិ។

៣-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ២០ (ម្ភៃ) ម៉ែត្រ គុណនឹង ៨០ (ប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] កែវ , ខាងត្បូងទល់ ឈុំ លីហោង , ខាងកើតទល់ [redacted] ផាណូល និងខាងលិចទល់ ផ្លូវជាតិ ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់កម្មសិទ្ធិលេខ ១៣១៤/១៩ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយ លោក [redacted] គឿន មេឃុំសាលាវិស័យ ប្រគល់ឱ្យដើមចោទជាគ្រប់គ្រងជាកម្មសិទ្ធិ ។

៤-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ១៤២ (មួយរយសែសិបពីរ) ម៉ែត្រ គុណនឹង ៣៨០ (បីរយប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ផ្លូវថ្នល់ , ខាងត្បូងទល់ [redacted] អ៊ិន , ខាងកើតទល់ [redacted] ប៊ុនថាន និងខាងលិចទល់ [redacted] អ៊ិន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្លង់ដីកម្មសិទ្ធិលេខ ១៣៧/២០ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ចេញដោយ លោក [redacted] គឿន មេឃុំសាលាវិស័យ ប្រគល់ឱ្យដើមចោទជាគ្រប់គ្រងជាកម្មសិទ្ធិ ។

ចំពោះបំណុលជំពាក់ធនាគារ គឺសុំបែងចែកដូចខាងក្រោម៖

១-ប្រាក់ជំពាក់នៅ ធនាគារ អេស៊ីលីដា ដែលមានប្រាក់កម្ចីដើមសរុបចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល និង ប្រាក់ជំពាក់នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ដែលមានប្រាក់កម្ចីដើមសរុបចំនួន ២៣.០០០ (ម្ភៃបីពាន់) ដុល្លាអាមេរិក ប្រគល់ឱ្យដើមចោទឈ្មោះ [redacted] ធារី ជាទទួលបន្ទុកសងម្នាក់ឯង ។

២-ប្រាក់ជំពាក់នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ដែលមានប្រាក់កម្ចីដើមសរុបចំនួន ១០.០០០.០០០ (ដប់លាន) រៀល និង ប្រាក់ជំពាក់នៅ ធនាគារ អ៊ឹរី (ខេមបូឌា) ម.ក ដែលមានប្រាក់កម្ចីដើមសរុបចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ប្រគល់ឱ្យចុងចម្លើយឈ្មោះ ឆាត វ៉ិត ជាទទួលបន្ទុកសងម្នាក់ឯង ។

២).សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ:

-ចុងចម្លើយឈ្មោះ [redacted] វ៉ិត បានធ្វើសេចក្តីថ្លែងការណ៍តបថា: ខ្ញុំបាទព្រមលែងលះជាមួយគាត់ ។ ខ្ញុំបាទប្រគល់សិទ្ធិឱ្យម្តាយជាអ្នកគ្រប់គ្រងកូនទាំងពីរនាក់ និងជួយអាហារកិច្ចចិញ្ចឹមកូនទាំងពីរតាមលទ្ធភាព។ ចំពោះទ្រព្យសម្បត្តិរួម ខ្ញុំឯកភាពដូចដើមចោទ គឺ

១-ឡានចំនួន ០១ (មួយ) គ្រឿង ម៉ាក CAMRY ផលិតឆ្នាំ២០០២ ពណ៌ទឹកមាស ពាក់ផ្លាកភ្នំពេញលេខ 2AI-2334 ជាទ្រព្យរួមប្តីប្រពន្ធ ខ្ញុំសុំទទួលយក ដោយប្រគល់ប្រាក់ចំនួន ៤០០០ (បួនពាន់) ដុល្លាអាមេរិក ឱ្យទៅដើមចោទ។

២-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ៨,៣០ (ប្រាំបីក្បៀសសាមសិប) ម៉ែត្រ គុណនឹង ១៧០ (មួយរយចិតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] ផាង , ខាងត្បូងទល់ [redacted] ជូ , ខាងកើតទល់ ផ្លូវជាតិលេខ៦២ និងខាងលិចទល់ [redacted] គឿន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ តាមរយៈលិខិត



Scanned with CamScanner

បញ្ជាក់ប្តូរដីលំនៅដ្ឋានលេខ ១៣៧/១៧ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ចេញដោយ លោក [redacted] មេឃុំសាលាវិស័យ ប្រគល់ឲ្យដើមចោទ។

៣-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ២០ (ម្ភៃ) ម៉ែត្រ គុណនឹង ៨០ (ប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] កែវ , ខាងត្បូងទល់ [redacted] លីហោង , ខាងកើតទល់ [redacted] ផាណូល និងខាងលិចទល់ ផ្លូវជាតិ ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់កម្មសិទ្ធិលេខ ១៣១៤/១៩ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយលោក [redacted] មេឃុំសាលាវិស័យ ប្រគល់ឲ្យដើមចោទ។

៤-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ១៤២ (មួយរយសែសិបពីរ) ម៉ែត្រ គុណនឹង ៣៨០ (បីរយប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ផ្លូវថ្នល់ , ខាងត្បូងទល់ [redacted] អ៊ិន , ខាងកើតទល់ [redacted] ប៊ុនថាន និងខាងលិចទល់ [redacted] អ៊ិន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្តូរដីកម្មសិទ្ធិលេខ ១៣៧/២០ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ចេញដោយ លោក [redacted] គឿន មេឃុំសាលាវិស័យ ប្រគល់ឲ្យដើមចោទ។

ចំពោះបំណុលជំពាក់ធនាគារ គឺសុំបែងចែកដូចខាងក្រោម៖

១-ប្រាក់ជំពាក់នៅ **ធនាគារ អេស៊ីលីដា** ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>២០.០០០.០០០ (ម្ភៃលាន) រៀល</u> និង ប្រាក់ជំពាក់នៅ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** ប្រាសាក់ ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>២៣.០០០ (ម្ភៃបីពាន់) ដុល្លារអាមេរិក</u> ប្រគល់ឲ្យដើមចោទឈ្មោះ ពៀន ធារី ជាអ្នកទទួលបន្ទុកសងម្នាក់ឯង ។

២-ប្រាក់ជំពាក់នៅ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត** ដែលមានប្រាក់កម្ចីដើមសរុបចំនួន ១០.០០០.០០០ (ដប់លាន) រៀល និង ប្រាក់ជំពាក់នៅ **ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>៤០.០០០.០០០ (សែសិបលាន) រៀល</u> ប្រគល់ឲ្យចុងចម្លើយឈ្មោះ [redacted] វុត ជាអ្នកទទួលបន្ទុកសងម្នាក់ឯង ។

**ឃ-ភស្តុតាង ៖**

-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ ។
-សំបុត្របញ្ជាក់កំណើតលេខ:៦៦ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ។
-សំបុត្របញ្ជាក់កំណើតលេខ:៨២២៨ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៥ ។
-សេចក្តីចម្លងសំបុត្រមរណភាព ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ។
-សៀវភៅគ្រួសារ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០១ ។
-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:១៥០៥២២៩៩២(០១) ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ ។
-កិច្ចសន្យាព្រមព្រៀងលែងលះគ្នា ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ ។
-លិខិតបញ្ជាក់ប្តូរដីកម្មសិទ្ធិលេខ:១៣៧/២០ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ។
-លិខិតបញ្ជាក់កម្មសិទ្ធិលេខ:១៣១៤/១៩ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ។
-លិខិតបញ្ជាក់ប្តូរដីលំនៅដ្ឋានលេខ:១៣៧/១៧ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ។
-កាលវិភាគសងប្រាក់ របស់ធនាគារអេស៊ីលីដា ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ ។
-តារាងកាលវិភាគសងប្រាក់ របស់ធនាគារអ៊ូរី (ខេមបូឌា) ម.ក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២។



Scanned with CamScanner

-កាលវិភាគសងប្រាក់ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ។

**ខ-ចំណុចទទាស ៖**

១-ដើមចោទថា ជំពាក់ប្រាក់ ធនាគារអេស៊ីលីដា ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ជាបំណុលរួម ប៉ុន្តែចុងចម្លើយ ថាខ្លួនមិនបានខ្ចីនោះទេ គឺដើមចោទខ្ចីប្រាក់ពីធនាគារតែម្នាក់ឯង ។

## សំអាងហេតុ

១/.ដើមចោទឈ្មោះ [redacted] ធារី និងចុងចម្លើយឈ្មោះ [redacted] រ៉ុត ពិតជាសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ និងបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍លេខ:៤៦ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានមានសំបុត្រអាពាហ៍ពិពាហ៍ជាសំអាង ហើយបានសុំលែងលះដោយឯកភាពគ្នា មានមូលហេតុច្បាស់លាស់ គប្បីតុលាការសម្រេចឱ្យលែងលះតាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី។

២/.លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា: កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ប៉ុន្តែមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍នោះ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ទើបដើមចោទ និងចុងចម្លើយ នាំគ្នាចុះបញ្ជីអាពាហ៍ពិពាហ៍ ហើយនៅក្នុងអំឡុងអាពាហ៍ពិពាហ៍ គូភាគីមានកូនចំនួន ២នាក់ គឺកូនទី១ ឈ្មោះ [redacted] រចនាសុភាវី ភេទស្រី សញ្ជាតិខ្មែរ កើតនៅថ្ងៃ០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ និងកូនទី២ ឈ្មោះ [redacted] សុនីតា ភេទស្រី សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ។ ក្រោយមក ការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ចេះតែឈ្លោះប្រកែកគ្នា ប្រើអំពើហិង្សាទៅវិញទៅមក អស់មនោសញ្ចេតនាជាប្តីប្រពន្ធ ដូច្នេះហើយ ទើបដាក់ពាក្យបណ្តឹងលែងលះមកតុលាការតែម្តង។ ចំពោះកូនទាំងពីរនាក់ កូនក្តីរបស់ខ្ញុំបាទ សុំសិទ្ធិគ្រប់គ្រង និងសុំបែងចែកទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

១-ឡានចំនួន ០១ (មួយ) គ្រឿង ម៉ាក CAMRY ផលិតឆ្នាំ២០០២ ពណ៌ទឹកមាស ពាក់ផ្លាកភ្នំពេញលេខ 2AI-2334 ជាទ្រព្យរួមប្តីប្រពន្ធ ប្រគល់ឱ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិ ដោយចុងចម្លើយយល់ព្រមប្រគល់ប្រាក់ចំនួន ៤០០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិក ឱ្យទៅចុងចម្លើយ។

២-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ៨,៣០ (ប្រាំបីក្បៀសសាមសិប) ម៉ែត្រ គុណនឹង ១៧០ (មួយរយចិតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] ធាង , ខាងត្បូងទល់ [redacted] ជូ , ខាងកើតទល់ ផ្លូវជាតិលេខ៦២ និងខាងលិចទល់ [redacted] គឿន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្លង់ដីលំនៅដ្ឋានលេខ <u>១៣៧/១៧</u> ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ចេញដោយ លោក [redacted] អន មេឃុំសាលាវិស័យ ជាទ្រព្យដើមរបស់ដើមចោទ សុំប្រគល់ឱ្យមកដើមចោទជាគ្រប់គ្រងជាកម្មសិទ្ធិ។

៣-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ២០ (ម្ភៃ) ម៉ែត្រ គុណនឹង ៨០ (ប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] កែវ , ខាងត្បូងទល់ [redacted] លីហោង , ខាងកើតទល់ [redacted] ផាណូល និងខាងលិចទល់ ផ្លូវជាតិ ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់កម្មសិទ្ធិលេខ <u>១៣១៤/១៩</u> ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយ លោក [redacted] មេឃុំសាលាវិស័យ ប្រគល់ឱ្យដើមចោទជាគ្រប់គ្រងជាកម្មសិទ្ធិ ។



Scanned with CamScanner

៤-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ១៤២ (មួយរយសែសិបពីរ) ម៉ែត្រ គុណនឹង ៣៨០ (បីរយប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ផ្លូវថ្នល់ , ខាងត្បូងទល់ [redacted] អ៊ិន , ខាងកើតទល់ [redacted] ប៊ុនថាន និងខាងលិចទល់ [redacted] អ៊ិន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្តូរដីកម្មសិទ្ធិលេខ ១៣៧/២០ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ចេញដោយ លោក [redacted] គឿន មេឃុំសាលាវិស័យ ប្រគល់ឲ្យដើមចោទជាគ្រប់គ្រងជាកម្មសិទ្ធិ ។

ចំពោះបំណុលជំពាក់ធនាគារ គឺសុំបែងចែកដូចខាងក្រោម៖

១-ប្រាក់ជំពាក់នៅ ធនាគារ អេស៊ីលីដា ដែលមានប្រាក់កម្ចីដើមសរុបចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល និង ប្រាក់ជំពាក់នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ដែលមានប្រាក់កម្ចីដើមសរុបចំនួន ២៣.០០០ (ម្ភៃបីពាន់) ដុល្លារអាមេរិក ប្រគល់ឲ្យដើមចោទឈ្មោះ [redacted] ធារី ជាអ្នកទទួលបន្ទុកសងម្នាក់ឯង ។

២-ប្រាក់ជំពាក់នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមរ៉េត ដែលមានប្រាក់កម្ចីដើមសរុបចំនួន ១០.០០០.០០០ (ដប់លាន) រៀល និង ប្រាក់ជំពាក់នៅ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ដែលមានប្រាក់កម្ចីដើមសរុបចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ប្រគល់ឲ្យចុងចម្លើយឈ្មោះ វាត វិត ជាអ្នកទទួលបន្ទុកសងម្នាក់ឯង ។

៣/.ចុងចម្លើយឈ្មោះ [redacted] វិត បានធ្វើសេចក្តីថ្លែងការណ៍តបថា: ខ្ញុំបាទព្រមលែងលះជាមួយគាត់ ។ ខ្ញុំបាទប្រគល់សិទ្ធិឲ្យម្តាយជាអ្នកគ្រប់គ្រងកូនទាំងពីរនាក់ និងជួយអាហារកិច្ចចិញ្ចឹមកូនទាំងពីរតាមលទ្ធភាព។ ចំពោះទ្រព្យសម្បត្តិរួម ខ្ញុំឯកភាពដូចដើមចោទ គឺ

១-ឡានចំនួន ០១ (មួយ) គ្រឿង ម៉ាក CAMRY ផលិតឆ្នាំ២០០២ ពណ៌ទឹកមាស ពាក់ផ្លាកភ្នំពេញលេខ 2AI-2334 ជាទ្រព្យរួមប្តីប្រពន្ធ ខ្ញុំសុំទទួលយក ដោយប្រគល់ប្រាក់ចំនួន ៤០០០ (បួនពាន់) ដុល្លារអាមេរិក ឲ្យទៅដើមចោទ។

២-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ៨,៣០ (ប្រាំបីក្បៀសសាមសិប) ម៉ែត្រ គុណនឹង ១៧០ (មួយរយចិតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] ផាង , ខាងត្បូងទល់ [redacted] ជួ , ខាងកើតទល់ ផ្លូវជាតិលេខ៦២ និងខាងលិចទល់ [redacted] គឿន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្តូរដីលំនៅឋានលេខ ១៣៧/១៧ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ចេញដោយ លោក [redacted] មេឃុំសាលាវិស័យ ប្រគល់ឲ្យដើមចោទ។

៣-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ២០ (ម្ភៃ) ម៉ែត្រ គុណនឹង ៨០ (ប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] កែវ , ខាងត្បូងទល់ ឈុំ លីហោង , ខាងកើតទល់ [redacted] ផាណូល និងខាងលិចទល់ ផ្លូវជាតិ ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់កម្មសិទ្ធិលេខ ១៣១៤/១៩ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយលោក [redacted] គឿន មេឃុំសាលាវិស័យ ប្រគល់ឲ្យដើមចោទ។



Scanned with CamScanner

៤-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ១៤២ (មួយរយសែសិបពីរ) ម៉ែត្រ គុណនឹង ៣៨០ (បីរយប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ផ្លូវថ្នល់ , ខាងត្បូងទល់ [redacted] អ៊ិន , ខាងកើតទល់ [redacted] ប៊ុនថាន និងខាងលិចទល់ [redacted] អ៊ិន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្លង់ដីកម្មសិទ្ធិលេខ <u>១៣៧/២០</u> ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ចេញដោយ លោក [redacted] គឿន មេឃុំសាលាវិស័យ ប្រគល់ឱ្យដើមចោទ។

ចំពោះបំណុលជំពាក់ធនាគារ គឺសុំបែងចែកដូចខាងក្រោម៖

១-ប្រាក់ជំពាក់នៅ **ធនាគារ អេស៊ីលីដា** ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>២០.០០០.០០០ (ម្ភៃលាន) រៀល</u> និង ប្រាក់ជំពាក់នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>២៣.០០០ (ម្ភៃបីពាន់) ដុល្លារអាមេរិក</u> ប្រគល់ឱ្យដើមចោទឈ្មោះ [redacted] ធារី ជាអ្នកទទួលបន្ទុកសងម្នាក់ឯង ។

២-ប្រាក់ជំពាក់នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ដែលមានប្រាក់កម្ចីដើមសរុបចំនួន ១០.០០០.០០០ (ដប់លាន) រៀល និង ប្រាក់ជំពាក់នៅ **ធនាគារ អ៊ីស៊ី (ខេមបូឌា) ម.ក** ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>៤០.០០០.០០០ (សែសិបលាន) រៀល</u> ប្រគល់ឱ្យចុងចម្លើយឈ្មោះ [redacted] វិត ជាអ្នកទទួលបន្ទុកសងម្នាក់ឯង ។

៤/.ដើមចោទ និងចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ដូចគ្នាថា: ពួកខ្លួនមានកូនជាមួយគ្នាចំនួន ២នាក់ កូនទី១ ឈ្មោះ [redacted] រចនាសុភាវី ភេទស្រី កើតនៅថ្ងៃ០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ សញ្ជាតិខ្មែរ និងកូនទី២ ឈ្មោះ [redacted] សុនីតា ភេទស្រី កើតនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ សញ្ជាតិខ្មែរ ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នា ឱ្យដើមចោទឈ្មោះ [redacted] ធារី ជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់ភាគីស្របតាមមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ។

៥/.ដើមចោទ និងចុងចម្លើយ បានសម្រេចបែងចែកទ្រព្យមានដូចខាងក្រោម៖

ក-ដើមចោទឈ្មោះ [redacted] ធារី ទទួលបានទ្រព្យសម្បត្តិរួមមាន៖

-ប្រាក់ចំនួន ៤000 (បួនពាន់) ដុល្លារអាមេរិក ពី ចុងចម្លើយឈ្មោះ [redacted] វិត ជាថ្លៃប្រគល់ឡានម៉ាក CAMRY ផលិតឆ្នាំ២00២ ពណ៌ទឹកមាស ពាក់ផ្លាកលេខភ្នំពេញ 2AI-2334 ទៅឱ្យចុងចម្លើយ ។

-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ៨,៣០ (ប្រាំបីក្បៀសសាមសិប) ម៉ែត្រ គុណនឹង ១៧០ (មួយរយចិតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] ផាង , ខាងត្បូងទល់ [redacted] ជួ , ខាងកើតទល់ ផ្លូវជាតិលេខ៦២ និងខាងលិចទល់ [redacted] គឿន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្លង់ដីលំនៅដ្ឋានលេខ <u>១៣៧/១៧</u> ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ចេញដោយ លោក [redacted] មេឃុំសាលាវិស័យ ជាទ្រព្យសម្បត្តិដើមរបស់ដើមចោទ ។

-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ២០ (ម្ភៃ) ម៉ែត្រ គុណនឹង ៨០ (ប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] កែវ , ខាងត្បូងទល់ [redacted] លីហោង , ខាងកើតទល់ សុខ ផាណូល និងខាងលិចទល់ ផ្លូវជាតិ ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់កម្មសិទ្ធិលេខ <u>១៣១៤/១៩</u>



Scanned with CamScanner

ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយលោក [redacted] គឿន មេឃុំសាលាវិស័យជាទ្រព្យសម្បត្តិដើមរបស់ដើមចោទ ។

-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ១៤២ (មួយរយសែសិបពីរ) ម៉ែត្រ គុណនឹង ៣៨០ (បីរយប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ផ្លូវថ្នល់ , ខាងត្បូងទល់ [redacted] អ៊ិន , ខាងកើតទល់ [redacted] ប៊ុនថាន និងខាងលិចទល់ [redacted] អ៊ិន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្លង់ដីកម្មសិទ្ធិលេខ <u>១៣៧/២០</u> ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ចេញដោយ លោក [redacted] មេឃុំសាលាវិស័យទ្រព្យសម្បត្តិដើមរបស់ដើមចោទ ។

ខ-ចុងចម្លើយឈ្មោះ [redacted] វុិត ទទួលបានទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

-ឡានចំនួន ០១ (មួយ) គ្រឿង ម៉ាក CAMRY ផលិតឆ្នាំ២០០២ ពណ៌ទឹកមាស ពាក់ផ្លាកភ្នំពេញលេខ 2AI-2334 ។

៦/.ដើមចោទ និងចុងចម្លើយ បានសម្រេចបែងចែកបំណុលរួមដូចខាងក្រោម៖

-ប្រាក់ជំពាក់នៅ **ធនាគារ អេស៊ីលីដា** ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>២០.០០០.០០០ (ម្ភៃលាន) រៀល</u> និង ប្រាក់ជំពាក់នៅ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** **ប្រាសាក់** ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>២៣.០០០ (ម្ភៃបីពាន់) ដុល្លារអាមេរិក</u> ប្រគល់ឱ្យដើមចោទឈ្មោះ [redacted] ធារី ជាអ្នកទទួលបន្ទុកសងម្នាក់ឯង ។

-ប្រាក់ជំពាក់នៅ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រ៉ឹត** ដែលមានប្រាក់កម្ចីដើមសរុបចំនួន ១០.០០០.០០០ (ដប់លាន) រៀល និង ប្រាក់ជំពាក់នៅ **ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>៤០.០០០.០០០ (សែសិបលាន) រៀល</u> ប្រគល់ឱ្យចុងចម្លើយឈ្មោះ [redacted] វុិត ជាអ្នកទទួលបន្ទុកសងម្នាក់ឯង ។

៧/.ភាគីដើមចោទពុំបានទាមទារឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីទេ គប្បីតុលាការឱ្យដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តីនេះ ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១/.ឱ្យដើមចោទឈ្មោះ [redacted] ធារី និងចុងចម្លើយឈ្មោះ [redacted] វុិត លែងលះគ្នា គិតចាប់ពីសាលក្រមនេះចូលជាស្ថាពរ ។

២/.កំណត់យកដើមចោទឈ្មោះ [redacted] ធារី ជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់ កូនទី១ ឈ្មោះ [redacted] រចនាសុភាវី ភេទស្រី កើតនៅថ្ងៃ០៥ ខែវិច្ឆិកា ឆ្នាំ២០១៦ សញ្ជាតិខ្មែរ និងកូនទី២ ឈ្មោះ [redacted] សុនីតា ភេទស្រី កើតនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ សញ្ជាតិខ្មែរ ។

៣/.បែងចែកទ្រព្យសម្បត្តិដូចខាងក្រោម៖

ក-ដើមចោទឈ្មោះ [redacted] ធារី ទទួលបានទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

-ប្រាក់ចំនួន ៤០០០ (បួនពាន់) ដុល្លារអាមេរិក ពី ចុងចម្លើយឈ្មោះ [redacted] វុិត ជាថ្លៃប្រគល់ឡានម៉ាក CAMRY ផលិតឆ្នាំ២០០២ ពណ៌ទឹកមាស ពាក់ផ្លាកលេខភ្នំពេញ 2AI-2334 ទៅឱ្យចុងចម្លើយ ។

-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ៨,៣០ (ប្រាំបីក្បៀសសាមសិប) ម៉ែត្រ គុណនឹង ១៧០ (មួយរយចិតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] ឆាង , ខាងត្បូងទល់ [redacted] ជូ , ខាងកើតទល់ ផ្លូវជាតិលេខ៦២

និងខាងលិចទល់ [redacted] គឿន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្លង់ដីលំនៅដ្ឋានលេខ <u>១៣៧/១៧</u> ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ចេញដោយ លោក [redacted] មេឃុំសាលាវិស័យជាទ្រព្យដោយឡែករបស់ដើមចោទ។

-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ២០ (ម្ភៃ) ម៉ែត្រ គុណនឹង ៨០ (ប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ [redacted] កែវ , ខាងត្បូងទល់ [redacted] លីហោង , ខាងកើតទល់ [redacted] ផាណូល និងខាងលិចទល់ ផ្លូវជាតិ ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់កម្មសិទ្ធិលេខ <u>១៣១៤/១៩</u> ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយលោក [redacted] គឿន មេឃុំសាលាវិស័យ ជាទ្រព្យដោយឡែករបស់ដើមចោទ។

-ដីលំនៅឋានចំនួន ០១ (មួយ) កន្លែង ទំហំ ១៤២ (មួយរយសែសិបពីរ) ម៉ែត្រ គុណនឹង ៣៨០ (បីរយប៉ែតសិប) ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់ ផ្លូវថ្នល់ , ខាងត្បូងទល់ [redacted] អ៊ិន , ខាងកើតទល់ [redacted] ប៊ុនថាន និងខាងលិចទល់ [redacted] អ៊ិន ស្ថិតនៅភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមរយៈលិខិតបញ្ជាក់ប្លង់ដីកម្មសិទ្ធិលេខ <u>១៣៧/២០</u> ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ចេញដោយ លោក [redacted] មេឃុំសាលាវិស័យ ជាទ្រព្យដោយឡែករបស់ដើមចោទ។

ខ-ចុងចម្លើយឈ្មោះ [redacted] រ៉ិត ទទួលបានទ្រព្យសម្បត្តិដូចខាងក្រោម៖

-ឡានចំនួន ០១ (មួយ) គ្រឿង ម៉ាក CAMRY ផលិតឆ្នាំ២០០២ ពណ៌ទឹកមាស ពាក់ផ្លាកភ្នំពេញលេខ 2AI-2334 ។

៤/.បំណុលរួមគូភាគីត្រូវទទួលខុសត្រូវដូចខាងក្រោម៖

-ប្រាក់ជំពាក់នៅ **ធនាគារ អេស៊ីលីដា** ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>២០.០០០.០០០ (ម្ភៃលាន) រៀល</u> និង ប្រាក់ជំពាក់នៅ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** ប្រាសាក់ ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>២៣.០០០ (ម្ភៃបីពាន់) ដុល្លារអាមេរិក</u> ប្រគល់ឲ្យដើមចោទឈ្មោះ [redacted] ធារី ជាអ្នកទទួលបន្ទុកសងម្នាក់ឯង ។

-ប្រាក់ជំពាក់នៅ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រ៉ឹត** ដែលមានប្រាក់កម្ចីដើមសរុបចំនួន ១០.០០០.០០០ (ដប់លាន) រៀល និង ប្រាក់ជំពាក់នៅ **ធនាគារ អ៊ីវ៉ី (ខេមបូឌា) ម.ក** ដែលមានប្រាក់កម្ចីដើមសរុបចំនួន <u>៤០.០០០.០០០ (សែសិបលាន) រៀល</u> ប្រគល់ឲ្យចុងចម្លើយឈ្មោះ [redacted] រ៉ិត ជាអ្នកទទួលបន្ទុកសងម្នាក់ឯង ។

៥/.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៦/.សាលក្រមនេះ បានទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខដើមចោទ និងចុងចម្លើយ ទុកសិទ្ធិឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃពុធ ៣រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅកំពង់ធំ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]



Scanned with CamScanner

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៣រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅកំពង់ធំ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner